ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃដំណើរទស្សនកិច្ចការងារ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំកំពូលពិសេសអាស៊ាន-សហរដ្ឋអាមេរិក នៅថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០២២ នៅរដ្ឋធានីវ៉ាស៊ីនតោន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបំពេញទស្សនកិច្ចការងារនៅសហរដ្ឋអាមេរិក ដើម្បីចូលរួមកិច្ចប្រជុំកំពូលពិសេសអាស៊ាន-សហរដ្ឋអាមេរិក នៅថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០២២ នៅរដ្ឋធានីវ៉ាស៊ីនតោន។ **សម្តេចតេជោ** ត្រូវបានអមដំណើរដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តមទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីអប់រំ យុវជន និងកីឡា **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីពាណិជ្ជកម្ម និងគណៈប្រតិភូជាន់ខ្ពស់ដទៃទៀត។ កិច្ចប្រជុំកំពូលនេះ គឺជាព្រឹត្តិការណ៍ពិសេសដ៏ចម្បងមួយ ធ្វើឡើងដើម្បីប្រារព្ធខួបលើកទី៤៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហរដ្ឋអាមេរិក និងដើម្បីដាក់ចេញនូវទិសដៅអនាគតនៃភាពជាដៃគូអាស៊ាន-សហរដ្ឋអាមេរិក។

ក្នុងនាមជាប្រធានអាស៊ាន **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានធ្វើជាសហប្រធានដឹកនាំសម័យប្រជុំពេញអង្គនៃកិច្ចប្រជុំកំពូលពិសេសនេះ ជាមួយ **ឯកឧត្តម ចូ បៃឌិន** ប្រធានាធិបតីសហរដ្ឋអាមេរិក និងបានអញ្ជើញចូលរួមកម្មវិធីផ្សេងៗទៀត ជាអាទិ៍រួមមាន ពិធីលៀងសាយភោជន៍ពេលល្ងាចថ្នាក់ប្រមុខរដ្ឋ/រដ្ឋាភិបាល ពិធីអាហារការងារថ្ងៃត្រង់ជាមួយសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យ និងគណបក្សសាធារណរដ្ឋ ដែលរៀបចំទទួលដោយ **លោកជំទាវ ណាន់ស៊ី ប៉េឡូស៊ី** ប្រធានសភាសហរដ្ឋអាមេរិក កិច្ចពិភាក្សារៀបចំធ្វើឡើងដោយ**លោកជំទាវ កាម៉ាឡា ហារីស** អនុប្រធានាធិបតីសហរដ្ឋអាមេរិក និងកម្មវិធីអន្តរកម្មនានា ជាមួយមេដឹកនាំធុរកិច្ចអាមេរិក។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

មេដឹកនាំអាស៊ាន និងប្រធានាធិបតីសហរដ្ឋអាមេរិក បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការពង្រឹង និងកសាងទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហរដ្ឋអាមេរិកឱ្យកាន់តែទូលំទូលាយថែមទៀតដែលមិនអាចខ្វះបានចំពោះអាស៊ាន និងសហរដ្ឋអាមេរិក ក៏ដូចជាសម្រាប់តំបន់ និងសហគមន៍អន្តរជាតិ។ ទំនាក់ទំនងទាំងនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់លើកកម្ពស់ និងរក្សាសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់។

ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២០២២នេះ ភាគីទាំងពីរប្តេជ្ញាបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-សហរដ្ឋអាមេរិក ដែលប្រកបដោយអត្ថន័យ មានខ្លឹមសារ និងផលប្រយោជន៍ទៅវិញទៅមក នៅឯកិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិកលើកទី១០ ដែលនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ នៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងរយៈពេលពីរថ្ងៃនៃកិច្ចប្រជុំកំពូលពិសេសនេះ ថ្នាក់ដឹកនាំបានពិភាក្សា និងផ្លាស់ប្តូរទស្សនៈគ្នាលើវិស័យនៃកិច្ចសហប្រតិបត្តិការជាច្រើន ដែលរួមមានការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ និងការស្តារឡើងវិញ ការលើកកម្ពស់ទំនាក់ទំនងសេដ្ឋកិច្ចឱ្យកាន់តែរឹងមាំថែមទៀត ការលើកកម្ពស់កិច្ចសហប្រតិបត្តិការលំហសមុទ្រ ការលើកកម្ពស់ការតភ្ជាប់រវាងប្រជាជន និងប្រជាជន ការគាំទ្រការអភិវឌ្ឍក្នុងអនុតំបន់ ការប្រើប្រាស់បច្ចេកវិទ្យា និងការលើកកម្ពស់នវានុវត្តន៍ ការដោះស្រាយការប្រែប្រួលអាកាសធាតុ និងការរក្សាសន្តិភាព និងការកសាងទំនុកចិត្ត។ ថ្នាក់ដឹកនាំបានធ្វើការអនុម័តសេចក្តីថ្លែងការណ៍ទស្សនៈវិស័យរួម ដោយអះអាងជាថ្មីនូវការប្តេជ្ញាចិត្ត ដើម្បីលើកកម្ពស់ភាពជាដៃគូអាស៊ាន-សហរដ្ឋអាមេរិក ជាពិសេស នៅក្នុងវិស័យទាំងនេះ។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិកាលំហសមុទ្រ និងការស្តារឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានសង្កត់ធ្ងន់ថា ពហុភាគីនិយម និងសហប្រតិបត្តិការអន្តរជាតិ គឺជាសរសរស្តម្ភសំខាន់ពីរ សម្រាប់ជានា និងថែរក្សាសន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍនតំបន់ និងសកលលោក។ **សម្តេចតេជោ**បានសម្តែងនូវការដឹងគុណចំពោះសហរដ្ឋអាមេរិក ដែលបានជួយឧបត្ថម្ភគាំទ្រការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅក្នុងតំបន់អាស៊ាន ដែលបានបង្កបរិយាកាសអំណោយផលដល់ការបើកសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ នៅកម្ពុជា ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២១មក។

នៅវិមានរដ្ឋសភា **សម្តេចតេជោនាយរដ្ឋមន្ត្រី** បានផ្តោតសុន្ទរកថាលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងប្រជាធិបតេយ្យនៅកម្ពុជា។ **សម្តេចតេជោ** បានធ្វើការកត់សម្គាល់ដោយសេចក្តីពេញចិត្តនូវសន្ទុះសហប្រតិបត្តិការប្រកបដោយចីរភាព នៅក្រោមផែនការការងារកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-អាមេរិក (TIFA) និងផែនការការងារការពង្រីកទំនាក់ទំនងសេដ្ឋកិច្ច (E3)។ **សម្តេចតេជោ** បានមានប្រសាសន៍ទៅកាន់មេដឹកនាំធុរកិច្ចអាមេរិកអំពីអាទិភាពបន្ទាន់នានា ដើម្បីស្តារឡើងវិញចេញពីវិបត្តិជំងឺកូវីដ-១៩ និងធ្វើឲ្យវិស័យពាក់ព័ន្ធទាំងអស់

មានថាមវន្តឡើងវិញ ក្នុងបំណងដើម្បីជំរុញកំណើនសេដ្ឋកិច្ចតំបន់ និងលើកស្ទួយការប្រកួតប្រជែង ពង្រឹងភាពធន់ បរិយាប័ន្ន និងការអភិវឌ្ឍប្រកបដោយចីរភាព។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តសហរដ្ឋអាមេរិកឲ្យផ្តល់នូវការគាំទ្ររឹងមាំថែមទៀតដល់ការអនុវត្តក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយ ការលើកស្ទួយការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងឌីជីថល។ **សម្តេចតេជោ** ក៏បានអំពាវនាវសុំឲ្យមានការលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកសុខភាពសាធារណៈ ការពង្រឹងនិម្មាបនកម្មសុខភាពសកល សម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតនាពេលអនាគត ក្នុងភាពជាដៃគូជាមួយអង្គការសុខភាពពិភពលោក។

នៅក្នុងអំឡុងពេលពិភាក្សាអំពីវិបានការអាកាសធាតុ បរិវត្តថាមពលស្អាត និងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានស្វាគមន៍ការបន្តប្តេជ្ញាចិត្តរបស់សហរដ្ឋអាមេរិក ចំពោះរបៀបវារៈបម្រែបម្រួលអាកាសធាតុ និងការវិលត្រឡប់ទៅរកកិច្ចព្រមព្រៀងទីក្រុងប៉ារីសវិញ។ **សម្តេចតេជោ** បានគូសបញ្ជាក់ថា សេចក្តីប្រាថ្នារបស់កម្ពុជា គឺធ្វើឲ្យកាន់តែស៊ីជម្រៅថែមទៀតនូវកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ បរិស្ថាន និងអន្តរកាលឆ្ពោះទៅថាមពលស្អាត កំណើនបៃតង ក៏ដូចជាដើម្បីលើកស្ទួយការអភិវឌ្ឍប្រកបដោយចីរភាព នៅក្នុងតំបន់។ **សម្តេចតេជោ** បានលើកឡើងអំពីសារៈសំខាន់នៃផែនការការងារសហប្រតិបត្តិការថាមពលអាស៊ាន-សហរដ្ឋអាមេរិក (២០២១-២០២៥) និងបានលើកឡើងអំពីសារៈប្រយោជន៍នៃកិច្ចប្រជុំរដ្ឋមន្ត្រីថាមពលអាស៊ាន-អាមេរិក ដែលបានប្រព្រឹត្តទៅកាលពីខែកញ្ញា ឆ្នាំ២០២១ កន្លងទៅ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា ទោះបីជាប្រទេសដែលបញ្ចេញឧស្ម័នកាបូនទាបក្តី កម្ពុជានៅតែប្តេជ្ញាចិត្តពេញលេញដើម្បីចូលរួមចំណែក ក្នុងកិច្ចខិតខំប្រឹងប្រែងសកលនេះ។

ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីតម្រូវការក្នុងការស្តារតម្លៃ និងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និងពិភពលោកឡើងវិញ ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃវិបត្តិជំងឺកូវីដ-១៩។ **សម្តេចតេជោ** បានបញ្ជាក់អំពីសារៈសំខាន់នៃការធ្វើសំយោគគ្នារវាងផែនការមេស្តីពីការតភ្ជាប់អាស៊ាន ឆ្នាំ២០២៥ (MPAC 2025) និងកម្មវិធីការតភ្ជាប់អាស៊ាន-សហរដ្ឋអាមេរិក, កម្មវិធីកំណើនរួមក្នុងតំបន់អាស៊ាន តាមរយៈនវានុវត្តន៍ ពាណិជ្ជកម្ម និងពាណិជ្ជកម្មអេឡិចត្រូនិក (IGNITE) របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID), និងគំនិតផ្តួចផ្តើមបណ្តាញចំណុចពណ៌ខៀវ (Blue Dot Network) ។ បន្ថែមលើនេះ **សម្តេចតេជោ** បានបញ្ជាក់ថា កម្ពុជាក៏មានក្តីរំភើបជាខ្លាំងចំពោះការរំពឹងទុករបស់អាស៊ាន និងសហរដ្ឋអាមេរិក ក្នុងការស្វែងយល់អំពីលទ្ធភាពអភិវឌ្ឍយុទ្ធសាស្ត្រយានយន្តអគ្គិសនី ដែលអាចគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃក្នុងទីក្រុងទូទាំងសហគមន៍អាស៊ាន។

នៅក្នុងអំឡុងពេលសម័យប្រជុំពេញអង្គនៃកិច្ចប្រជុំកំពូលពិសេសនេះ **សម្តេចតេជោ** និងមេដឹកនាំអាស៊ានដទៃទៀត បានសម្តែងការគាំទ្រដល់ការលើកកម្ពស់ទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-

សហរដ្ឋអាមេរិក ទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ហើយបានធ្វើការប្ដេជ្ញាចិត្តរួមគ្នា ធ្វើការយ៉ាងជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក ដើម្បីធានាថា កិច្ចសហប្រតិបត្តិការលើវិស័យអាទិភាពទាំងអស់ដែលបានលើកឡើងនៅក្នុងអំឡុងពេលពីរថ្ងៃនៃកិច្ចពិភាក្សា នឹងនាំមកនូវផលប្រយោជន៍ជាក់ស្ដែងទៅវិញទៅមកចំពោះប្រជាជនអាស៊ាន និងសហរដ្ឋអាមេរិក ក៏ដូចជាចូលរួមចំណែកដល់សន្តិភាព ស្ថិរភាព និងកំណើនវិបុលភាពតំបន់។

ពាក់ព័ន្ធនឹងបញ្ហាតំបន់ និងអន្តរជាតិ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានអះអាងឡើងវិញអំពីជំហរបស់កម្ពុជាពាក់ព័ន្ធនឹងវិបត្តិអ៊ុយក្រែន-រុស្ស៊ី ហើយទទូចឲ្យមានការបន្តកិច្ចសន្ទនានយោបាយទូលំទូលាយមួយ ដើម្បីបញ្ចប់ភាពប្រទូស្តរាយ និងស្ដារសន្តិភាពឡើងវិញ។ កម្ពុជាគាំទ្រទាំងស្រុងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយវិបត្តិមនុស្សធម៌ និងដើម្បីស្វែងរកដំណោះស្រាយសន្តិភាពមួយ ដើម្បីបញ្ចប់ជម្លោះនេះ។ ពាក់ព័ន្ធនឹងស្ថានការណ៍នៅមីយ៉ាន់ម៉ា **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់អំពីការប្ដេជ្ញាចិត្តដ៏មុតមាំរបស់កម្ពុជា ដើម្បីនាំមកនូវវឌ្ឍនភាពលើអាទិភាពបន្ទាន់បី ជាអាទិ៍រួមមាន៖ បញ្ចប់អំពើហិង្សា សម្របសម្រួលជំនួយមនុស្សធម៌ឲ្យទៅដល់ប្រជាជនដែលមានសេចក្ដីត្រូវការបំផុត ហើយបង្កើតបរិយាកាសអំណោយផលមួយ ដើម្បីឲ្យមានកិច្ចសន្ទនានយោបាយមួយក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងជូននូវជំហរប្រកបដោយសង្គតិភាពរបស់កម្ពុជា ដើម្បីថែរក្សាសមុទ្រចិនខាងត្បូង ជាសមុទ្រសន្តិភាព ស្ថិរភាព និងសហប្រតិបត្តិការ។ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានឆ្លៀតឱកាសបញ្ជាក់ឡើងវិញនូវការប្ដេជ្ញាចិត្តរបស់កម្ពុជា ដើម្បីអនុវត្តឲ្យបានម៉ឺងម៉ាត់នូវមាត្រាទាំងឡាយនៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលពុំអនុញ្ញាតឲ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីកម្ពុជា។

នៅអំឡុងពេលបិទកិច្ចប្រជុំកំពូលពិសេសនេះ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណ**ឯកឧត្តមប្រធានាធិបតី ចូ បៃឌិន** ដែលបានធ្វើការប្ដេជ្ញាគាំទ្រភាពជាប្រធានអាស៊ានរបស់កម្ពុជា ហើយទន្ទឹងរង់ចាំស្វាគមន៍ឯកឧត្តមប្រធានាធិបតី អញ្ជើញមកចូលរួមកិច្ចប្រជុំកំពូល អាស៊ាន-សហរដ្ឋអាមេរិក នៅកម្ពុជា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ នេះ។

នៅអំឡុងពេលស្នាក់អាស្រ័យនៅទីក្រុងវ៉ាស៊ីនតោន **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ក៏មានជំនួបជាមួយឯកឧត្តម ផាម មីនជីញ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងបានជួបសំណេះសំណាលរាក់ទាក់ជាមួយពលរដ្ឋខ្មែរ-អាមេរិកជាង២ពាន់នាក់ ដែលបានអញ្ជើញមកជួបជុំគ្នា នៅទីក្រុងវ៉ាស៊ីនតោន ដើម្បីស្វាគមន៍**សម្ដេចតេជោ**៕

ថ្ងៃសៅរ៍ ១៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០២២